# រឿង មហាចោរនៅទល់ដែន

**ភាគទី៧**

ក្នុងមួយវិនាទីនោះ វិសេសក្លាហានចូលប្រកៀកនឹងខ្លួនកាមា ហូតយកដាវដែលព្យួរនៅចង្កេះគ្រវាត់ឮប្រាវលើក្តារ ធែកធេរមើលសព្វហោប៉ៅពុំឃើញមានអាវុធអ្វីទៀត ក៏បញ្ជាឲ្យកាមាអង្គុយលើកៅអីជិតនោះ កាមាធ្វើតាមបង្គាប់។ មួយសន្ទុះក្រោយមក ចង្កៀងខ្វាញ់ក៏ភ្លឺឡើង កាមាញញឹមយ៉ាងខែងរកវិសេសក្លាហាន ដែលប្រុងស្មារតីគ្មានធ្វេសសោះឡើយ។

- មើលរឿងអ្វី ?
- សូមលោកអ៊ំ មើលទៅបន្ទាប់កូនស្រីលោកអ៊ំមើល។

វិសេសក្លាហានងាកទៅមើលទ្វារ ឃើញចំហមួយប្រលោះខ្ទួន។ លោកភ្ញាក់ខ្លួនខ្វាក ស្ទង់ដឹងស្ថានការណ៍កើតសង្ស័យ ចិត្តក្តៅក្តួល។ កាមាកាន់ជ័យជំនះមួយយ៉ាងអស្ចារ្យនៅពេលនោះ។

- សូមលោកអ៊ំអញ្ជើញចូលមើលលើគ្រែកូនស្រីលោកអ៊ំមើល។

វិសេសក្លាហានស្ទុះក្ញែតចូលក្នុងបន្ទប់នារី យកចុងដាវវាត់បើកមុងមានតែពូក និងខ្នើយ។ ចិត្តមោហោមួយយ៉ាងរំពងក្នុងរាត្រីស្ងាត់ថា៖

- ហាស់ ! កូនស្រី ! ទេវី !

សូរសម្រែកឮបានតែប៉ុណ្ណោះតាចាស់យើងដួលផ្ងាខ្លួនទៅក្រោយសន្លប់បាត់ស្មារតី។ កាមាឃើញដូច្នោះ ក៏ក្រោកពីកៅអីឈានជើងទៅយកដាវខ្លួនដែលដេកលើក្តារមកស៊កចូលក្នុងស្រោមដូចមុន រួចផ្ទោះតាមបង្អួចទៅបាត់ក្នុងទីងងឹតទៅ។ សម្រែកវិសេសក្លាហានលាន់ឮស្ទើររហែកមេឃ។ សូរសម្រែកបោះពួយក្នុងអាកាសទៅដល់ត្រចៀកនាងទេវី ដែលកំពុងនិយាយលេងយ៉ាងរីករាយជាមួយមានន្ទជាគូគាប់ នាងឈប់ង៉ក់ដូចគេកន្ត្រាក់។ កញ្ញាងើបក្បាលឡើងពីជង្គង់មានន្ទដោយបើកភ្នែកធំៗ ។ ដើមទ្រូងនាងញ័រយ៉ាងខ្លាំង។ ស្រីហាក់ដឹង

រឿងអាសន្នអស់។ នាងប្រាទមាននូវរឹងដែលដួលទៅក្រោយ រួចរត់សំដៅទៅផ្ទះ។ មានន្ទ ស្រឡាំងកាំងក្រោកឡើងបោសគូទស្រែកដោយសម្លេងហៅនាង៖

- ឈប់ៗ រឿងអ្វី? ទេវីអូន!

តែនារីទៅឆ្ងាយណាស់ទៅហើយ បុរសក៏ដើរតាមក្រោយនាងទៅ ដោយឈានជើង យ៉ាងវែងៗ ប្រញាប់ប្រញាល់ឲ្យបានទាន់គួជីតាពន្លឺចង្កៀងចោះប្រលោះមួយយ៉ាងជំក្នុង អាកាសងងឹត តាមទ្វារខ្ទមដែលចំហ។ នាងទេវីទុចជើងដោយបានឃើញពន្លឺនេះ។

ពន្លឺធ្វើឲ្យនាងកើតក្តីខ្លាច តែទោះដល់មរណៈក៏ដោយនាងត្រូវតែចូលទៅរកពន្លឺនេះ។ ព្រលឹងនៅចុងសក់ កញ្ញាប្រឹងទប់សន្តានចិត្តកុំឲ្យជ្រួលច្របល់ពេក តែឥតប្រយោជន៍។ ស្រី ដឹងមុនថា ទុក្ខមួយយ៉ាងធំនឹងមានដល់នាងក្នុងមួយភ្លែតទៀតនេះ តែនាងយល់ថាចៀសទុក្ខ នេះមិនបានផុតទេ នាងត្រូវតែប៉ះទង្គិចជាដាច់ខាត។ នាងនឹកថា មិនអីទេខ្លួននាងខុស ហើយ នាងព្រមទទួលទុក្ខទាំងអស់ដោយឥតប្រកែក តែពុំដឹងជាទុក្ខនោះ មានភាព រឺ បែបយ៉ាង ណានៅឡើយ។

កល្យាណកើតមានមនោសញ្ចេតនាមួយថ្មីដែលមកសណ្ឋិតក្នុងខ្លួននាង គឺចង់ដឹង។ នាងឈានជើងមួយៗចូលក្នុងផ្ទះយ៉ាងមានះ ដោយធ្មេចភ្នែកកុំឲ្យឃើញពន្លឺដ៏មហិមានេះ។ មួយជំហានដែលនាងដើរ ជីតាហាក់ឃើញឧបសគ្គកាន់តែធំឡើង។ ខ្លួន ស្រីព្រលឹងហាក់ចេះ តែថយក្រោយទៅវិញ។ មួយជំហានដែលនាងបានបោះកន្លងរួចមកហើយ គឺឧបសគ្គមួយ ដែលនាងឆ្លងរួច ស្រីហាក់បានធូរចិត្តបន្តិច។ ផ្ទះស្ងាត់ឈឹង ទេវីតែតែឆ្ងល់ទៅទៀត។ នាងដើរ ដល់មាត់ទ្វារ។ នាងដកដង្ហើមធំម្តង។ នាងអើតមុខចូលខាងក្នុងផ្ទះ។ ឱ! រឿងអីដូច្នោះ? នាង ឃើញឪពុកនាងដួលដេកលើក្តារសន្ទប់បាត់ស្មារតីឥតដឹងខ្លួន។ យុវតីខ្លោចចិត្តអាណិតឪពុក។ នាងយំយ៉ាងខ្លោចផ្សា ហើយរត់ទៅបីត្រកងលោកឪពុកជាអ្នកមានគុណ ផ្តេកក្បាលដាក់ លើភ្លៅនាង។ បុត្រីអង្រួនដាស់បិតា តែគ្មានពាក្យអ្វីសួរ អ្វីឆ្លើយសោះ។ កញ្ញាភិតភ័យកាន់តែ ខ្លាំងឡើងៗ។ កល្យាណងើបមុខឡើងឃើញម៉ែក្មួង នាងទ្រហោយំថា៖

- ម៉ែក្មួង ជួយផង! ជួយឪពុកខ្ញុំផង លោកកើតអី?

អត្ថបទដោយ៖ មាស សុភាព

*នាងក្ដួងទឹកភ្នែករហាមដៃរឱបជើងវិសេសក្វាហានយំដូចកូនក្មេង។*

- *ម៉ែក្ដួងៗ ទៅរកទឹកមួយផ្តិលមក ឆាប់ៗ ម៉ែក្ដួង។*

*លុះបានទឹកមក នាងទេវីលាបមុខលោកឪពុក លាបដៃជើង និង សព្វសព៌ាង្គកាយ។ គាប់ជួនពេលនោះ ព្រលឹងវិសេសក្វាហានក៏ចូលមកសណ្ឋិតកាន់រូបវិញធ្វើឲ្យមេទ័ពចាស់ងាកក្បាលចុះឡើងៗ។ នាងទេវីត្រេកអរក្រៃលែង ដូចបានឃើញឪពុកនាងមានកំនើតជាថ្មី។ ស្រីខំដាស់បោសអង្អែលទាំងទឹកភ្នែកថា៖*

- *លោកពុក លោកពុក នេះកូន ស្គាល់កូនទេ លោកពុក ពុកកើតអ្វី?*

*ដំបូងវិសេសក្វាហានហាក់ភ្ញាក់ពីដេក។ លោកព្រមាត់កូនលោកខ្សាវ រួចសូរមាត់បុត្រីនេះព្រកាន់តែខ្លាំងឡើងៗ។ លោកបើកភ្នែកឃើញនាងទេវីឱបលោក ឃើញនាងក្ដួងនៅទ្រចុងជើងលោក។ មួយស្របក់ក្រោយមក កម្លាំងក៏កាន់តែមានឡើងវិញបន្តិចម្ដងៗ ទើបវិសេសក្វាហាននឹកឃើញរឿងដែលនាំឲ្យលោកដេកដួលនៅទីនេះ។*

*សេចក្ដីក្រោធខឹងមួយឆួលឆេះឡើងយ៉ាងពេញទំហឹង មករោលរាលរូបគាត់។ គាត់ក្រោកអង្គុយសម្ងឹងមើលមុខនាងទេវីមិនដាក់ភ្នែក។ លោកច្រានកែវដែលធ្លាប់ជាពន្ធកចេញពីខ្លួនលោក កុំឲ្យស្រីអប្បលក្ខណ៍កាន់សាច់លោកទៀត។ នាងទេវីធ្ងល់ ធ្ងល់នឹងកាយវិការនេះ ទើបនាងនឹកភ្ញៃតឡើងថា លោកឪពុកនាងជ្រាបរឿងនេះហើយ។ នាងលុតជង្គង់ ដៃទាំងពីរខ្ទប់មុខយំព្រឃឹកៗ។ កញ្ញាពោលទាំងត្រដាបត្រដួសថា៖*

**(សូមរង់ចាំតាមដានភាគទី៨ នៅសប្ដាហ៍ក្រោយ)**

*អត្ថបទដោយ៖ មាស សុភាព*